# តំបន់ខ្ពង់រាបបាតសមុទ្រ

កាលពីមុន តំបន់ខ្ពង់រាបបាតសមុទ្រ (continental self: CS) មិនសូវមានរដ្ឋចាប់អារម្មណ៍ ច្រើនទេ។ ក្រោយមក ដោយសារតំបន់នេះសំបូរធនធានប្រេង និងបច្ចេកវិទ្យាទំនើប ដែលអនុញ្ញាតឲ្យរដ្ឋអាចទាញយកធនធានពីតំបន់នេះបាន ទើបនាំឲ្យមានការចាប់ផ្តើមទាមទារតំបន់នេះ។ ឆ្នាំ១៩៤៥ ប្រធានាធិបតី Truman នៃសហរដ្ឋអាមេរិក បានថ្លែងទាមទារ។ ក្នុងឆ្នាំ១៩៥៨ អង្គការសហប្រជាជាតិបានអនុម័តអនុសញ្ញាស្តីពីខ្ពង់រាបបាតសមុទ្រ។

តំបន់នេះមានតំបន់បាតសមុទ្រ (seabed) និងដីក្រោមបាតសមុទ្រ (subsoil)។ ចម្ងាយទទឹងនៃតំបន់នេះ អាស្រ័យទៅតាមស្ថានភាពភូមិសាស្ត្រ។ រដ្ឋជាប់ឆ្នេរ (coastal state) មានសិទ្ធិអធិបតេយ្យរហូតដល់២០០ ម៉ាលសមុទ្រគិតពីខ្សែបន្ទាត់មូលដ្ឋាន ដោយស្វ័យប្រវត្តិ (មិនចាំបាច់ទាមទារ)។ ក្នុងករណីមានពន្លយពីធម្មជាតិតពីដីគោក (natural prolongation) រហូតដល់រឹមនៃទ្វីប (continental margin) ប្រវែងទទឹងអាចមានលើសពី២០០ ម៉ាលសមុទ្រ។ មានវិធីសាស្ត្រយ៉ាងតិចពីរទៀត ដែលរដ្ឋអាចប្រើដើម្បីវាស់ទទឹងនៃ CS។ **ទី១.** ចម្ងាយពី១០០ ម៉ាលពីចំណុចដែលមានជម្រៅទឹក ២៥០០ ម៉ែត្រអ៊ីសូបាត (កាលពីមុន១០០ ម៉ែត្រ ក្រោយមក១០០០ម៉ែត្រ) **និងទីពីរ៖** ចម្ងាយ៦០ម៉ាលពីគែមខាងក្រៅនៃជម្រាលទ្វីប (continental slope)។ ទោះបីយ៉ាងនេះក្តីទទឹងនៃ CS ពីខ្សែបន្ទាត់មូលដ្ឋានមិនត្រូវលើស៣៥០ម៉ាលឡើយ។

ក្នុងតំបន់ខ្ពង់រាបបាតសមុទ្រនេះ រដ្ឋមានសិទ្ធិអធិបតេយ្យពេញលេញក្នុងការធ្វើអាជីវកម្មលើរ៉ែ បាតសមុទ្របូក្រោមបាតសមុទ្រ។

រដ្ឋជាប់ឆ្នេរមានសិទ្ធិពន្លាតតំបន់សមុទ្រនេះរហូតដល់ចម្ងាយអតិប្បរមា៣៥០ម៉ៃល៍សមុទ្រ ដោយផ្អែកតាមលក្ខខណ្ឌភូគព្ភសាស្ត្រនិងភូមិសណ្ឋានសាស្ត្រ និងស្របតាមនីតិវិធី ដូចមានចែងក្នុង UN-CLoS។ ក្នុងករណីដែលរដ្ឋជាប់ឆ្នេរ ចង់ពន្លាតខ្ពង់រាបបាតសមុទ្ររបស់ខ្លួនលើសពី២០០ម៉ៃល៍សមុទ្រ រដ្ឋត្រូវដាក់សំណើទៅគណៈកម្មការទទួលបន្ទុកកំណត់តំបន់ខ្ពង់រាបបាតសមុទ្រ (Commission on the Limits of the Continental Shelf)។ គណៈកម្មការនេះនឹងចេញជាអនុសាសន៍ ក៏ប៉ុន្តែមិនចងជា កាតព្វកិច្ចនិងមិនប៉ះពាល់ដល់ការកំណត់ព្រំដែនសមុទ្រណាមួយឡើយ។

- ក្នុងតំបន់ខ្ពង់រាបបាតសមុទ្រ រដ្ឋមានសិទ្ធិអធិបតេយ្យលើការរុករក និងធ្វើអាជីវកម្មលើ ធនធានធម្មជាតិរួមទាំងប្រេងកាតនិងធនធានរ៉ែផ្សេងៗទៀតផងកសាងកោះសិប្បនិម្មិត។

-រដ្ឋជាប់ឆ្នេរចែករំលែកផលនៃអាជីវកម្មកទទួលបាន ក្នុងចំងាយហួសពី២០០ម៉ាលជាមួយ សហគមន៍អន្តរជាតិ។

-រដ្ឋដទៃមានសិទ្ធិធ្វើនាវាចរ ហោះហើរនិងដាក់ខ្សែកាបឬបំពង់បង្ហូរប្រេងឬឧស្ម័ន ឆ្លងកាត់តំបន់នេះ (អនុសញ្ញា UNCLoS ឆ្នាំ១៩៨២, មាត្រា៧៦-៧៧)។

## មាត្រា៧៦នៃអនុសញ្ញា UNCLoS ចែងអំពីខ្ពង់រាបបាតសមុទ្រ៖

1. The continental shelf of a coastal State comprises the seabed and subsoil of the submarine areas that extend beyond its territorial sea throughout the natural prolongation of its land territory to the outer edge of the continental margin, or to a distance of 200 nautical miles from the baselines from which the breadth of the territorial sea is measured where the outer edge of the continental margin does not extend up to that distance.

2. ……